**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរំឭកបន្ថែមអំពីវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស

ទោះបីស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ មានលក្ខណៈធូរស្រាល ក៏ក្រសួងសុខាភិបាលនៅតែបន្តដាក់វិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺនេះ។ ក្នុងន័យនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមរំឭកសារជាថ្មីម្តងទៀតដល់ម្ចាស់រោងចក្រ សហគ្រាស ជាពិសេសរោងចក្រក្នុងវិស័យកាត់ដេរ ត្រូវបន្តអនុវត្តឱ្យបានត្រឹមត្រូវតាមសេចក្តីណែនាំនានារបស់ក្រសួងសុខាភិបាលពាក់ព័ន្ធនឹងវិធានការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ ជាពិសេសត្រូវបន្តៈ

១. រៀបចំឱ្យមានការវាស់កម្តៅគ្រប់បុគ្គលទាំងអស់ មុនពេលអនុញ្ញាតឱ្យចូលក្នុងបរិវេណរោងចក្រ សហគ្រាស ជាពិសេសអគារផលិតកម្ម និងត្រូវអនុញ្ញាតឱ្យកម្មករនិយោជិតទៅពិគ្រោះយោបល់ជាមួយពេទ្យ ឬអ្នកជំនាញប្រសិនកម្មករនិយោជិតណាម្នាក់មានរោគសញ្ញាក្អក ហៀរសំបោរ ឈឺបំពង់ក ពិបាកដកដង្ហើម និងមានកម្តៅខ្លួនលើសពី ៣៧,៥អង្សា។

២. រៀបចំឱ្យមានទឹកអាល់កុល ឬជែលលាងដៃ ឬសាប៊ូលាងដៃនៅតាមមាត់ច្រកចេញចូលអគារ សម្រាប់កម្មករនិយោជិតលាងសំអាតដៃមុនពេលចូលក្នុងរោងចក្រ សហគ្រាស។

៣. ត្រូវរៀបចំបម្រុងទុកម៉ាសឱ្យបានគ្រប់គ្រាន់ សម្រាប់បើកផ្តល់ដល់កម្មករនិយោជិត តាមវេជ្ជបញ្ជារបស់ពេទ្យអាស្រ័យលើស្ថានភាពសុខភាព និងស្ថានភាពទូទៅរបស់កម្មករនិយោជិតម្នាក់ៗ។

៤. ត្រូវរំឭកកម្មករនិយោជិតនៅពេលដែលក្អក កណ្តាស់ ត្រូវខ្ទប់មាត់ ច្រមុះ ដោយប្រើកន្សែង ក្រមា ឬកែងដៃ រួចបោះចោលក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ បន្ទាប់មកត្រូវលាងសម្អាតដៃនឹងសាប៊ូ ឬទឹកអាល់កុល។

៥. រាយការណ៍ទៅលេខទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ឬលេខទូរស័ព្ទណាមួយដែលផ្តល់ដោយក្រសួងសុខាភិបាល ប្រសិនជាមានកម្មករនិយោជិតណាម្នាក់មានកម្តៅខ្លួនលើសពី ៣៧,៥អង្សា និងមានរោគសញ្ញាមួយយ៉ាងតិច ដូចជាក្អក ហៀរសំបោរ ឈឺបំពង់ក ដង្ហើមខ្លី ឬពិបាកដកដង្ហើម និងមានប្រវត្តិធ្វើដំណើរទៅតំបន់ដែលមានកើតជំងឺកូវីដ-១៩ និងបានប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩ ឬអ្នកស្លាប់ដោយសារជំងឺស្រួចស្រាវដោយមិនដឹងពីអត្តសញ្ញាណ ឬប៉ះពាល់ជាមួយសត្វឈឺក្នុងអំឡុងពេល ១៤ថ្ងៃ មុនចេញរោគសញ្ញា ។

ក្រសួងសូមថ្លែងអំណរគុណដល់ម្ចាស់រោងចក្រ សហគ្រាស សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ដែលបានចាត់វិធានការបន្ថែមជាវិជ្ជមាននាពេលកន្លងមក។

សេចក្តីដូចមានជម្រាបជូនខាងលើ សូម ម្ចាស់ ឬនាយករោងចក្រ សហគ្រាស កម្មករនិយោជិត និងអង្គការវិជ្ជាជីវៈទាំងអស់ជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ អង្គារ ១២កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែមិថុនា ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩